អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សេចក្តីប្រកាសព័ត៌មានពីអង្គភាពជនរងគ្រោះ

អង្គភាពជនរងគ្រោះមានក្តីរីករាយនឹងប្រកាសជូនដំណឹងអំពីការទទួលបានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន៩៤។ ចំនួនសរុបនេះគឺទទួលបាននៅមុនថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០៩ ដែលជាកាលបរិច្ឆេទកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងសម្រាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមក្នុងដំណើរការសំណុំរឿងលេខ០០១។ សំណុំរឿងលេខ០០១ គឺជាការចោទប្រកាន់លើឧក្រិដ្ឋកម្មប្រព្រឹត្តដោយជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅឌុច នៅឯមន្ទីរសន្តិបាល ស-២១ (ទួលស្លែង) មន្ទីរសន្តិបាលស-២៤ (ព្រៃស) និងទីវាលពិឃាត ជើងឯក។

ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នោះរួមមានអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន២៨ ត្រូវបានទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេតរួចមកហើយកាលពីក្នុងដំណាក់កាលស៊ើបអង្កេត។ តាមរយៈលទ្ធផលនៃសកម្មភាពការងារផ្សព្វផ្សាយដែលបានធ្វើឡើងទាក់ទងនឹងដំណើរការចាប់ផ្តើមនៃសវនាការជំនុំជម្រះក្តីលើសំណុំរឿង០០១នេះ  អង្គភាពជនរងគ្រោះបានទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន៦៦ បន្ថែមទៀត។

បណ្តឹងគឺមានតួនាទីសំខាន់ខ្លាំងណាស់សម្រាប់អ.វ.ត.ក។ ព័ត៌មានទាំងឡាយដែលផ្តល់ដោយអ្នកដាក់ពាក្យបណ្តឹងហើយគ្មានបំណងក្លាយជាភាគីនៅក្នុងដំណើរការនីតិវិធី គឺអាចមានសារៈប្រយោជន៍សម្រាប់ការិយាល័យសហព្រះរាជអាជ្ញា។ បណ្តឹងទាំងអស់អាចប្រើប្រាស់ជាភស្តុតាងសម្រាប់សវនាការជំនុំជម្រះ ហើយអ្នកប្តឹងអាចក្លាយទៅជាសាក្សីសម្រាប់សហព្រះរាជអាជ្ញា។ ដោយគិតមកត្រឹមថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០៩  អង្គភាពជនរងគ្រោះបានទទួលនូវពាក្យបណ្តឹងចំនួន២៨ ទាក់ទងនឹងសំណុំរឿងលេខ០០១ នេះ។ ដោយសារតែការទទួលពាក្យបណ្តឹងគ្មានកាលបរិច្ឆេទកំណត់នោះ ដូច្នេះហើយអង្គភាពជនរងគ្រោះនឹងនៅតែបន្តទទួល និងដំណើរការទៅលើពាក្យបណ្តឹងផ្សេងៗ ទៀតដែលទទួលបានពីជនរងគ្រោះ និងបញ្ជូនពាក្យបណ្តឹង ទាំងអស់នោះទៅកាន់ការិយាល័យសហព្រះរាជអាជ្ញា។

ECCC, National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia
Tel: +(855) 023 219 814 Fx: +(855) 023 219 841 Web: www.eccc.gov.kh

លោកស្រីគាត បូផល ប្រធានអង្គភាពជនរងគ្រោះបានមានប្រសាសន៍ថា *“នាងខ្ញុំសូមថ្លែងអំណរគុណដល់បណ្ដាអន្ដរការីទាំងអស់ដែលបានជួយក្នុងដំណើរការនេះ ដល់បណ្ដាប្រព័ន្ធផ្សព្វផ្សាយទាំងអស់ដែលបានជួយផ្សាយព័ត៌មាន និងបណ្ដាបុគ្គលិកអ.វ.ត.ក ទាំងអស់ដែលបានខិតខំប្រឹងប្រែង ហើយជាពិសេសសូមសម្ដែងនូវការកោតសរសើរយ៉ាងខ្ពង់ខ្ពស់ជូនដល់ជនរងគ្រោះទាំងអស់ដែល មានការប្ដេជ្ញាចិត្តខ្ពស់ក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។”*

សូមកត់សំគាល់ផងដែរថាសវនាការបឋមសម្រាប់សំណុំរឿង០០១ ដែមានជនជាប់ចោទឈ្មោះកាំង ហ្គេកអ៊ាវ ហៅឌុច  នឹងប្រព្រឹត្តធ្វើឡើងនាថ្ងៃទី១៧ ខែកុម្ភះ ឆ្នាំ២០០៩ វេលាម៉ោង៩ ព្រឹក។